**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រាក់ឧបត្ថម្ភវេនយាមប្រចាំការជូនមន្ត្រីរាជការ នៅតាម មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់អំពីប្រាក់ឧបត្ថម្ភវេនយាមប្រចាំការជូនមន្ត្រីក្របខណ្ឌសុខាភិបាលនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព លើកលែងតែអង្គភាពនោះបានក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបម្រើវិស័យសុខាភិបាលនិងសេវាសុខភាពសាធារណៈកាន់តែមានប្រសិទ្ធភាពខ្ពស់។

**មាត្រា ២.-**

ប្រាក់ឧបត្ថម្ភវេនយាមប្រចាំការ ត្រូវកំណត់ដូចខាងក្រោមនេះ៖

- មន្ត្រីក្របខណ្ឌសុខាភិបាលជាន់ខ្ពស់ គ្រូពេទ្យមធ្យម ឱសថការីមធ្យម និងទន្តពេទ្យមធ្យម ទទួលប្រាក់ឧបត្ថម្ភ ក្នុង១ (មួយ) វេនយាមប្រចាំការ (២៤ម៉ោង) ចំនួន ២០ ០០០ (ពីរម៉ឺន) រៀល ក្នុងមួយនាក់
- មន្ត្រីក្របខណ្ឌសុខាភិបាលមធ្យមនិងបឋម ទទួលប្រាក់ឧបត្ថម្ភ ក្នុង១ (មួយ) វេនយាមប្រចាំការ (២៤ម៉ោង) ចំនួន ១៥ ០០០ (មួយម៉ឺនប្រាំពាន់) រៀលក្នុងមួយនាក់
- មន្ត្រីក្របខណ្ឌរដ្ឋបាលទូទៅ ទទួលប្រាក់ឧបត្ថម្ភ ក្នុង១ (មួយ) វេនយាមប្រចាំការ (២៤ម៉ោង) ចំនួន ១០ ០០០ (មួយម៉ឺន) រៀលក្នុងមួយនាក់។

ប្រាក់ឧបត្ថម្ភវេនយាមប្រចាំការខាងលើ មិនអាចផ្តល់លើសពី១០ (ដប់) វេន ក្នុង១ខែបានឡើយ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ